អេស៊ីលីដា
ACLEDA BANK

# របាយការណ៍ប្រចាំត្រីមាសទី១

## គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាលានរៀល) | ត្រីមាសទី១ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ៣៨.២៥៣.៩៣៥ | ៣៧.១៨១.២៩៩ | ៣២.០០២.២៩៨ |
| បំណុលសរុប | ៣២.៧៦៥.៣៩០ | ៣១.៧៦០.៦៦០ | ២៧.០៩២.៩៨៥ |
| មូលធនសរុប | ៥.៤៨៨.៥៤៥ | ៥.៤២០.៦៣៩ | ៤.៩០៩.៣១៣ |
| **លទ្ធផលហិរញ្ញវត្ថុ (គិតជាលានរៀល)** | **ត្រីមាសទី១ ឆ្នាំ២០២៣** | **ត្រីមាសទី១ ឆ្នាំ២០២២** | **ត្រីមាសទី១ ឆ្នាំ២០២១** |
| ចំណូលសរុប | ៨២៦.៧៧០ | ៧០៩.៦៩៦ | ៦៣៨.១៧៨ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | ១៩១.៣៨៥ | ១៧៩.៦៨២ | ២១០.៦៩៣ |
| ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ | ១៥៧.៤២៤ | ១៤៣.៦១០ | ១៧៩.០៥២ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ៦៧.៩០៦ | ១០៩.០០៥ | ១៧៩.០២៩ |
| **អនុបាតហិរញ្ញវត្ថុ (%)** | **ត្រីមាសទី១ ឆ្នាំ២០២៣** | **ឆ្នាំ២០២២** | **ឆ្នាំ២០២១** |
| អនុបាតសាធនភាព | ១៨,៧៥% | ១៩,២៥% | ២២,៣៦% |
| អនុបាតបំណុលធៀបនឹងមូលធន | ៥៩៦,៩៨% | ៥៨៥,៩២% | ៥៥១,៨៧% |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព | ២២៨,២១% | ១៥៤,៩៦% | ១៥៥,៦៥% |
| អនុបាតឥណទានមិនដំណើរការ (*) | ៣,២១% | ២,៩០% | ២,៣៣% |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ៩៦,៩៥% | ១០០,៥១% | ៩៤,៩៧% |
| តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១២.៦១៤ | ១២.៤៥៦ | ១១.២៧៧ |
| | **ត្រីមាសទី១ ឆ្នាំ២០២៣** | **ត្រីមាសទី១ ឆ្នាំ២០២២** | **ត្រីមាសទី ១ ឆ្នាំ២០២១** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)(**) | ០,៤២% | ០,៤៤% | ០,៦៦% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE)(**) | ២,៩០% | ២,៩១% | ៣,៩៩% |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ដង) | ១,៦២ | ១,៩២ | ២,៣៦ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៣៦៣,០៣ | ៣៣១,២៩ | ៤១៤,៥៦ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | គ្មាន | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | គ្មាន | គ្មាន | គ្មាន |

(*) ឥណទានមិនដំណើរការ = ឥណទាននៅដំណាក់កាលទី៣

(**) . អនុបាតទាំងនេះមិនមែនជាអនុបាតប្រចាំឆ្នាំនោះទេ ហើយត្រូវបានគណនាដោយប្រើតួលេខប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគាររយៈពេល ៣ខែ ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

. ចំណេញធៀបនឹងទ្រព្យសកម្មមធ្យម = ប្រាក់ចំណេញក្នុងការិយបរិច្ឆេទដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / ទ្រព្យសកម្មសរុបមធ្យម

. ចំណេញធៀបនឹងមូលធនមធ្យម = ប្រាក់ចំណេញក្នុងការិយបរិច្ឆេទដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / មូលធនសរុបមធ្យមរបស់ភាគហ៊ុនិករបស់ធនាគារ

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប







អនុបាតហិរញ្ញវត្ថុ (%)
៥៩៦,៩៨%
៥៨៥,៩២%
៥៥១,៨៧%
២២៨,២១%
១៥៥,៦៥%
១៥៤,៩៦%
១០០,៥១%
៩៦,៩៥%
៩៤,៩៧%
២២,៣៦%
១៩,២៥%
១៨,៧៥%
៣,២១%
២,៩០%
២,៣៣%
អនុបាតសាធនភាព
អនុបាតបំណុលធៀប នឹងមូលធន
អនុបាតក្របខ័ណ្ឌ សន្ទនីយភាព
អនុបាតឥណទាន មិនដំណើរការ
អនុបាតឥណទានធៀប នឹងប្រាក់បញ្ញើ
ត្រីមាសទី១ ឆ្នាំ២០២៣
ឆ្នាំ២០២២
ឆ្នាំ២០២១


៣,៩៩%
២,៩០%
២,៩១%
០,៤២%
០,៤៤%
០,៦៦%
អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)
អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE)
ត្រីមាសទី១ ឆ្នាំ២០២៣
ត្រីមាសទី១ ឆ្នាំ២០២២
ត្រីមាសទី១ ឆ្នាំ២០២១


ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
៤១៤,៥៦
៣៣១,២៩
៣៦៣,០៣
ត្រីមាសទី១ ឆ្នាំ២០២១
ត្រីមាសទី១ ឆ្នាំ២០២២
ត្រីមាសទី១ ឆ្នាំ២០២៣


តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
១១.២៧៧
១២.៤៥៦
១២.៦១៤
ឆ្នាំ២០២១
ឆ្នាំ២០២២
ត្រីមាសទី១ ឆ្នាំ២០២៣

# សមាសភាពក្រុមប្រឹក្សាភិបាល



**លោក ឆាយ សឿន**
*ប្រធានក្រុមប្រឹក្សាភិបាល*



**បណ្ឌិត អ៊ិន ចាន់នី**
*អភិបាលប្រតិបត្តិ*



**លោក Stéphane Mangiavacca**
*អភិបាលមិនប្រតិបត្តិ*



**លោក Kyosuke Hattori**
*អភិបាលមិនប្រតិបត្តិ*



**លោក Albertus Bruggink**
*អភិបាលមិនប្រតិបត្តិ*



**លោក កាយ ឡូត**
*អភិបាលមិនប្រតិបត្តិ*



**លោក Pieter Kooi**
*អភិបាលឯករាជ្យ*



**លោក វ៉ាន់ ស៊ូអៀង**
*អភិបាលឯករាជ្យ*



**លោកស្រី ភូរិ រតនា**
*អភិបាលឯករាជ្យ*

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

តាងនាមឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ”) និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយសូមផ្តល់ជូនរបាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ (“សម្ព័ន្ធធនាគារ”) គិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ដល់ភាគីពាក់ព័ន្ធទាំងអស់។

នៅក្នុងឆ្នាំ២០២៣ សេដ្ឋកិច្ចពិភពលោកអាចនឹងមានកំណើនក្នុងអត្រាប្រហែល ២,៨% ដោយសារសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន សម្ពាធអតិផរណានៅតែបន្តមាន ភាពតានតឹងភូមិសាស្ត្រនយោបាយ និងការរឹតបន្តឹងរូបិយវត្ថុរបស់ធនាគារកណ្តាលទូទាំងពិភពលោកក្នុងការគ្រប់គ្រងសម្ពាធអតិផរណាខ្ពស់។ ទន្ទឹមនឹងនេះ កត្តាដែលជះឥទ្ធិពលដល់សេដ្ឋកិច្ចពិភពលោក ក៏បានធ្វើឱ្យសេដ្ឋកិច្ចអាស៊ានរងផលប៉ះពាល់ និងមានកំណើនយឺតយ៉ាវផងដែរ។

ទោះបីជាទស្សនវិស័យសេដ្ឋកិច្ចពិភពលោកមានសភាពមិនច្បាស់លាស់ក្តី ប៉ុន្តែចាប់ពីពាក់កណ្តាលឆ្នាំ២០២២ សេដ្ឋកិច្ចកម្ពុជាមានសន្ទុះនៃការរីកចម្រើនឡើងវិញគួរឱ្យកត់សម្គាល់ ដោយសារការបន្តនូវសកម្មភាពពាណិជ្ជកម្មដ៏រឹងមាំ កំណើនការនាំចេញ ជាពិសេសក្នុងវិស័យផលិតកម្ម និងកសិកម្ម ការងើបឡើងវិញនៃវិស័យសេវាកម្ម និងសន្ទុះនៃលំហូរការវិនិយោគដោយផ្ទាល់ពីបរទេស ដែលនាំឱ្យកំណើនសេដ្ឋកិច្ចត្រូវបានគេរំពឹងថានឹងពង្រីកក្នុងអត្រាប្រែប្រួលចន្លោះពី ៥,២-៦,២% បន្ទាប់ពីកំណើនប៉ាន់ស្មាន ៥,២% ក្នុងឆ្នាំ២០២២។

នៅកំលុងត្រីមាសទី១ ឆ្នាំ២០២៣នេះ ធនាគារ បានទទួលពាន និងបណ្ណសរសើរ ជាធនាគារឆ្នើម ពីនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) ដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច ដែលបានចុះបញ្ជីបរធនបាលកិច្ច បានច្រើនជាងគេ ប្រចាំឆ្នាំ២០២២ បន្ទាប់ពីធនាគារទទួលបានការអនុញ្ញាតពី ន.ប.ធ. ធ្វើជាប្រតិបត្តិករបរធនបាល។ ជាងនេះទៅទៀត ធនាគារបានចាប់ដៃគូជាមួយ RIA Money Transfer ក្នុងការពង្រីកសេវាកម្មផ្ទេរប្រាក់ ហើយភាពជាដៃគូនេះ បានបន្ថែមទីតាំងដកប្រាក់ និងទូទាត់ប្រាក់ជាច្រើនកន្លែង តាមរយៈបណ្តាញរបស់ RIA នៅក្នុងប្រទេសកម្ពុជា។ ធនាគារបានបន្តធ្វើឱ្យប្រសើរឡើងនូវមុខងារស្វ័យប្រតិបត្តិការជាច្រើនលើ**អេស៊ីលីដាម៉ូបាល** យូអរកូដ ម៉ាស៊ីនអេធីអឹម និងម៉ាស៊ីនឆូតកាតស្របតាមតម្រូវការរបស់អតិថិជន និងវិវឌ្ឍនាការបច្ចេកវិទ្យាឌីជីថល។ ទន្ទឹមនឹងនេះ ធនាគារបានពង្រីកសេវាកម្មធនាគារស្វ័យប្រវត្តិចំនួន**១៤០**ទីតាំង (រាជធានីភ្នំពេញចំនួន**៥៣**ទីតាំង និងបណ្តាខេត្តសរុបចំនួន**៨៧**ទីតាំង) បន្ថែមលើសាខាធនាគារទាំង**២៦៤**សាខា ព្រមទាំងបានបំពាក់ម៉ាស៊ីនអេធីអឹមចំនួន**១.០៥៤**គ្រឿង ម៉ាស៊ីនឆូតកាតចំនួន**៤.០២២**គ្រឿង និងយូអរកូដតាមសំណើសុំរបស់អតិថិជនសម្រាប់ប្រតិបត្តិការនៃការផ្ទេរ និងការទូទាត់នៅតាមបណ្តាផ្សារ ហាងទំនិញ សណ្ឋាគារ គ្រឹះស្ថានសិក្សា មន្ទីរពេទ្យ ទីភ្នាក់ងារទេសចរណ៍ ស្ថានីយ៍ប្រេងឥន្ធនៈ និងអាជីវកម្មនានានៅទូទាំងប្រទេស។ គិតត្រឹមដំណាច់ត្រីមាសទី១ ឆ្នាំ២០២៣នេះ ធនាគារ មានដៃគូអាជីវកម្មសរុបជាង **០,២៤**លាន និងមានអ្នកប្រើប្រាស់**អេស៊ីលីដាម៉ូបាល**សរុបចំនួន **២,៨៤**លាននាក់។

គិតត្រឹមដំណាច់ត្រីមាសទី១ ឆ្នាំ២០២៣នេះ សម្ព័ន្ធធនាគារសម្រេចបាននូវលទ្ធផលជាវិជ្ជមាន ដោយទ្រព្យសកម្មសរុបបានកើនឡើងចំនួន៨០៤,៩៣លានដុល្លារអាមេរិក ឬ៤,៤៨% និងទ្រព្យសកម្មឥណទានសរុបបានកើនឡើងចំនួន១៥៩,៥៩លានដុល្លារអាមេរិក ឬ២,៤៩% ធៀបនឹងដំណាច់ឆ្នាំ២០២២។

សម្ព័ន្ធធនាគារទទួលបានប្រាក់ចំណេញដែលផ្តល់ជូនភាគហ៊ុនិករបស់ធនាគារ (សម្រាប់ខែមករា កុម្ភៈ និងមីនា ឆ្នាំ២០២៣) សរុបចំនួន៣៨,៥០លានដុល្លារអាមេរិក ខណៈដែលអនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យមមានចំនួន០,៤២% និងអនុបាតចំណេញធៀបនឹងមូលធនមធ្យមមានចំនួន២,៩០%។

ជាទីបញ្ចប់ ខ្ញុំបាទសូមថ្លែងអំណរគុណ និងសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះភាគីពាក់ព័ន្ធទាំងអស់ដែលបានបន្តផ្តល់ការគាំទ្រដល់ធនាគារ។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣
ហត្ថលេខា និងត្រា

**ឆាយ សឿន**

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... ii

សមាសភាពក្រុមប្រឹក្សាភិបាល ..... v

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ..... vi

**ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១**

**ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១**

**ខ- លក្ខណៈនៃធុរកិច្ច ..... ១**

**គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១**

**ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ..... ៣**

**ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ..... ៣**

**ខ- រចនាសម្ព័ន្ធចំណូល ..... ៦**

**ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ ..... ៦**

**ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ..... ៧**

**ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ..... ៧**

**ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ..... ១០**

**គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ..... ១២**

**ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ..... ១២**

**ង- ផលប៉ះពាល់នៃអតិផរណា ..... ១២**

**ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ..... ១២**

**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១៥**

# ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ អេស៊ីលីដា ភីអិលស៊ី** |
| ជាអក្សរឡាតាំង | **ACLEDA Bank Plc.** |
| លេខកូដស្តង់ដារ | KH១០០០១០០០០៣ |
| ទីស្នាក់ការ | អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (០)២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ |
| លេខទូរសារ | +៨៥៥ (០)២៣ ៤៣០ ៥៥៥ |
| គេហទំព័រ | www.acledabank.com.kh |
| អ៊ីម៉ែល | acledabank@acledabank.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៣០៧៧ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ០៦ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ចេញដោយ ធនាគារជាតិ នៃ កម្ពុជា |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ០៥៣/២០គ.ម.ក./ស.ស.រ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ចេញដោយនិយ័តករមូលបត្រកម្ពុជា “ន.ម.ក.” (ពីមុនជា គណៈកម្មការមូលបត្រកម្ពុជា “គ.ម.ក.”) |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | **បណ្ឌិត អ៊ិន ចាន់នី** |

## ខ- លក្ខណៈនៃធុរកិច្ច

ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារពាណិជ្ជដែលមានសាខា និងបណ្តាញការិយាល័យធំជាងគេបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា (ផមក) ចាប់តាំងពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។ បច្ចុប្បន្ននេះ ធនាគារមានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន៤ រួមមាន៖ (១) ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត (២) ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា (៣) ក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី និង (៤) វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ព្រមទាំងមានការិយាល័យតំណាងចំនួន១នៅប្រទេសមីយ៉ាន់ម៉ា។

## គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

- នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា បានទទួលវិញ្ញាបនបត្រ ដែលទទួលស្គាល់ជាធនាគារ ដែលមានសុវត្ថិភាពទិន្នន័យស្តង់ដារឧស្សាហកម្មប័ណ្ណទូទាត់ (PCI DSS) ជំនាន់ ៣.២.១ ពីស្ថាប័ន Control Case LLC ដែលជាភ្នាក់ងារវាយតម្លៃសុវត្ថិភាព ដ៏ល្បីល្បាញ និងទទួលស្គាល់ជាអន្តរជាតិ និងមានការិយាល័យស្ថិតនៅក្នុងសហរដ្ឋអាមេរិក។
- នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៣ ធនាគារបានទទួលពានរង្វាន់ឈានមុខគេប្រចាំឆ្នាំ២០២១ និង២០២២ សរុបចំនួន៩ពានរង្វាន់ពីស្ថាប័នវីសា ដែលជាក្រុមហ៊ុននាំមុខគេក្នុងបច្ចេកវិទ្យាទូទាត់សាច់ប្រាក់តាមរយៈប្រព័ន្ធឌីជីថល។ នេះជាសក្ខីភាពសបញ្ជាក់ថា ធនាគារ អេស៊ីលីដា ជាធនាគារដែលឆ្នើមឈានមុខគេក្នុងប្រទេសកម្ពុជា ដែលបានទទួលពានរង្វាន់ភាពជាអ្នកដឹកនាំឆ្នើមចំនួន

៩ រួមមាន៖ (១) Leadership in Spend Per Active Card (For Visa Debit In Affluent Segment 2021), (២) Leadership in Domestic Merchant (Sales Volume 2021), (៣) Leadership in Ecommerce Merchant (Sales Volume 2021), (៤) Leadership in Transaction Per Active (Terminal 2021), (៥) Leadership in Active Caids 2021, (៦) Leadership in Credit Card Issurance 2021, (៧) Leadership in Domestic Merchant (Sales Volume 2022), (៨) Leadership in Ecommerce Merchant (Sales Volume 2022) និង (៩) Leadership in Active Caids 2022។

- នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣ ធនាគារ បានទទួលលិខិតកោតសរសើរ និងថ្លែងអំណរគុណ ពីមូលនិធិគន្ធបុប្ផាកម្ពុជា ចំពោះការចូលរួមបរិច្ចាគដ៏សំខាន់ និងជាបន្តបន្ទាប់ ជូនមូលនិធិគន្ធបុប្ផាកម្ពុជា ក្នុងការរួមគ្នារក្សានិរន្តរភាពនៃកិច្ចដំណើរការរបស់មន្ទីរពេទ្យគន្ធបុប្ផា។
- នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ គណៈប្រតិភូមកពីធនាគារកណ្តាលហ្វីជី និងធនាគារកណ្តាលកោះសូឡូម៉ូន មកទស្សនកិច្ចសិក្សាផ្ទាល់នៅធនាគារ អេស៊ីលីដា។ ធនាគារ អេស៊ីលីដា ជាធនាគារពាណិជ្ជមួយ ដែលផ្តល់សេវាធនាគារបែបឌីជីថលដ៏សម្បូរបែប ជាពិសេសសេវាធនាគារតាមប្រព័ន្ធបាគងឈានមុខមួយក្នុងវិស័យធនាគារនៅកម្ពុជា។
- នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ ធនាគារ បានទទួលលិខិតថ្លែងអំណរគុណ និងកោតសរសើរពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលធនាគារបានចូលរួមបំពេញកាតព្វកិច្ចបង់ពន្ធដារផ្ទៃក្នុងជូនរដ្ឋ និងជាសហគ្រាសជាប់ "ចំណាត់ថ្នាក់លេខ៣" ក្នុងចំណោមសហគ្រាស ដែលបានបង់ពន្ធច្រើនជាងគេ និងទទួលបានអនុលោមភាពសារពើពន្ធប្រភេទ **"មាស"** ក្នុងឆ្នាំ២០២២។
- នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ ធនាគារបានទទួលពាន និងបណ្ណសរសើរ ជាធនាគារឆ្នើម ពីនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) ដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច ដែលបានចុះបញ្ជីបរធនបាលកិច្ច ច្រើនជាងគេ ក្នុងឆ្នាំ២០២២ បន្ទាប់ពីធនាគារទទួលបានការអនុញ្ញាតពី ន.ប.ធ. ធ្វើជាប្រតិបត្តិករបរធនបាល។
- នៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ ថ្នាក់ដឹកនាំ និងកម្មករនិយោជិតធនាគារ អេស៊ីលីដា គ្រប់លំដាប់ថ្នាក់នៅការិយាល័យកណ្តាល និងសាខាជុំវិញរាជធានីភ្នំពេញ បានចូលរួមបរិច្ចាគឈាមដោយស្ម័គ្រចិត្ត ដើម្បីជួយសង្គ្រោះជនរងគ្រោះ និងអ្នកជំងឺ ដែលត្រូវការឈាម។ នេះសបញ្ជាក់ឱ្យឃើញថា ធនាគារបានចូលរួមចំណែកក្នុងសកម្មភាពសង្គម និងមនុស្សធម៌ សម្រាប់បំពេញតម្រូវការកង្វះឈាមក្នុងការជួយសង្គ្រោះអាយុជីវិតជូនដល់មជ្ឈមណ្ឌលជាតិផ្តល់ឈាម។
- នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ធនាគារ បានទទួលលិខិតថ្លែងអំណរគុណពីគណៈកម្មការអន្តរក្រសួងរៀបចំពិធីបុណ្យទន្លេ ដែលធនាគារបានចូលរួមឧបត្ថម្ភថវិកាសម្រាប់ទ្រទ្រង់ដល់ការរៀបចំ **ពិធីបុណ្យទន្លេលើកទី៧** ប្រារព្ធធ្វើឡើងនៅខេត្តកំពង់ធំ ក្រោមប្រធានបទ "**ទន្លេរបស់យើង ដើម្បីបច្ចុប្បន្ន និងអនាគត**" ដែលរៀបចំដោយ **ក្រសួងទេសចរណ៍** ដើម្បីរួមចំណែកដល់ការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាឱ្យទទួលបានការរីកចម្រើនជាបន្តបន្ទាប់។
- នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ធនាគារបានចុះអនុស្សរណៈយោគយល់គ្នាជាមួយ **សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA)** ក្នុងគោលបំណងដើម្បីសហការគ្នាក្នុងការផ្តល់សេវាពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋក្រីក្រទូទាំងព្រះរាជាណាចក្រកម្ពុជា។ នេះសបញ្ជាក់ឱ្យឃើញថា ធនាគារបានចូលរួមក្នុងសកម្មភាពមនុស្សធម៌ក្នុងបុព្វហេតុប្រជាពលរដ្ឋ និងសង្គម ដើម្បីគាំទ្រដល់សុខុមាលភាពសាធារណៈ ព្រមទាំងចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងសម្រាលបន្ទុកចំណាយជូនប្រជាពលរដ្ឋ។
- នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ធនាគារបានទទួលបណ្ណថ្លែងអំណរគុណ ពី**សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA)** ដែលធនាគារបានឧបត្ថម្ភថវិកាសម្រាប់ចូលរួមចំណែកក្នុងការផ្តល់សេវាថែរក្សាសុខភាព ក្នុងការពិនិត្យ និងការព្យាបាលជំងឺនៅតាមមូលដ្ឋានដោយឥតគិតថ្លៃ ក្នុងបុព្វហេតុលើកកម្ពស់សុខុមាលភាពជូនដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេស។

- នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ ធនាគារបានចាប់ដៃគូជាមួយ RIA Money Transfer ក្នុងការពង្រីកសេវាកម្មផ្ទេរប្រាក់នៅកម្ពុជា។ ការពង្រីកបណ្តាញរបស់ RIA រួមមានសេវាកម្មមានភាពងាយស្រួល ដូចជាការទូទាត់សាច់ប្រាក់ ការប្រមូលសាច់ប្រាក់ទាំងប្រាក់រៀល (ប្រាក់រៀលកម្ពុជា) និងដុល្លារអាមេរិក (ដុល្លារសហរដ្ឋអាមេរិក) និងគណនីបញ្ញើ។

# ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

- **ប្រតិបត្តិការក្នុងវិស័យធនាគារ**

ត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២២ ធនាគារពាណិជ្ជមានចំនួន៥៩ (ធនាគារក្នុងស្រុកចំនួន២៧ បុត្រសម្ព័ន្ធធនាគារបរទេសចំនួន១៨ និងសាខាធនាគារបរទេសចំនួន១៤) ធនាគារឯកទេសចំនួន០៩ (ធនាគារក្នុងស្រុកចំនួន០៤ និងធនាគារបរទេសចំនួន០៥) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៨៧ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន០៥ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន៨២) ក្រុមហ៊ុនភតិសន្យាចំនួន១៦ ការិយាល័យតំណាងធនាគារបរទេសចំនួន០៦ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន៣៤ និងគ្រឹះស្ថានឥណទានជនបទចំនួន២២៤។ (Source: NBC Report, CMA Report, and Actually Updated)

- **ប្រតិបត្តិការអាជីវកម្ម និងចំណែកទីផ្សាររបស់ធនាគារ អេស៊ីលីដា នៅក្នុងវិស័យធនាគារ**

គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២២ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានចំណែកទីផ្សារសម្រាប់ប្រាក់បញ្ញើសន្សំចំនួន ១៦,១៣% និងសម្រាប់ឥណទានចំនួន ១៣,៦១%។

គិតត្រឹមដំណាច់ខែមីនា ឆ្នាំ២០២៣ ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី១ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
| **សេវាឥណទាន** | | | |
| ចំនួនឥណទានសកម្ម | ៦០៧.១២៩ | ៥៩១.៤៩៤ | ៥៤១.១៨៤ |
| សមតុល្យឥណទានសរុប (លានរៀល) | ២៦.៦៨០.៣៤០ | ២៦.៤៣៧.៩២៨ | ២២.១១៦.០១៣ |
| **សេវាបញ្ញើ-សន្សំ** | | | |
| ចំនួនគណនីសរុប | ៤.០៦៨.០៤០ | ៣.៨៦៥.៧៤៩ | ៣.២៩៨.៣៨២ |
| សមតុល្យប្រាក់បញ្ញើសរុប (លានរៀល) | ២៧.៥២០.៧៨៥ | ២៦.៣០៣.៤៧៥ | ២៣.២៨៧.០៦៤ |
| **សេវាធនាគារអេឡិចត្រូនិក** | | | |
| **ប័ណ្ណអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណបោះផ្សាយសរុប | ១.៨៥០.៩៨៥ | ១.៧៩៩.៩០៩ | ១.៥៨៥.៨៤៩ |
| ចំនួនប្រតិបត្តិការសរុប | ៥.០៤៧.៥១០ | ២១.០៥៨.៦០៩ | ១៩.៤៤៨.៨៣៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៤.៦០៨.៣៨០ | ១៨.៦៨៣.៣៣៥ | ១៦.១៧៣.៩៩០ |
| **អេស៊ីលីដាម៉ូបាល** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ២.៩៨០.៧៩៣ | ២.៨៤៥.៨៨៦ | ២.២៧៨.២២០ |
| ចំនួនប្រតិបត្តិការសរុប | ៧១.៤៩០.៧៨៨ | ១៤៨.៧៩៩.៦៦១ | ៧៨.៧២៦.៨៩៥ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី១ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៨៥.៧៤៥.០១៦ | ២០៦.៦៦០.២៦២ | ១១៥.២៤២.៦៣៨ |
| **អេស៊ីលីដាអ៊ីនធើណែត** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ២២.៩៣៦ | ២២.១៦៤ | ១៣.៥៥៧ |
| ចំនួនប្រតិបត្តិការសរុប | ៧៤២.៧៤៨ | ២.៣១៨.៧៨៩ | ១.៤៦៦.៨២២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៦.៧៨១.៨០៨ | ២៦.១៥៨.៧០៥ | ១៩.៧៩៩.៨៦៤ |
| **អេស៊ីលីដាអ៊ីខុមមើស** | | | |
| ចំនួនដៃគូអាជីវកម្មសរុប | ៨១ | ៧៣ | ៥៩ |
| ចំនួនប្រតិបត្តិការសរុប | ៩៧៥.៥២៥ | ៣.៦១៩.៩៣៦ | ៣.២១៥.២០៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៦៨៤.៤៦១ | ១.៨០៤.១៣៦ | ១.២០៦.៥២៩ |
| **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនសរុប | ១.១១៤ | ១.១១៤ | ៩០១ |
| ចំនួនប្រតិបត្តិការសរុប | ៩.៧៥៨.៧០៥ | ៣៥.២៩៨.២១៤ | ២៧.១២៩.២៥២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១១.១៩១.៦៤២ | ៣៩.១៦០.៩៧៦ | ២៦.៤៧៧.៣៤១ |
| **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** | | | |
| ចំនួនម៉ាស៊ីនសរុប | ២៦ | ២៦ | ២៦ |
| ចំនួនប្រតិបត្តិការសរុប | ១៣១ | ១.៤៨៧ | ៤.១២០ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៣.៤០៦ | ១១១.១៣៤ | ៣៤៣.១៥៨ |
| **ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម** | | | |
| ចំនួនម៉ាស៊ីនសរុប | ៩៦ | ៤៣ | ២៥ |
| ចំនួនប្រតិបត្តិការសរុប | ២៨.៦០២ | ៤៣.០៨៩ | ៣៤.០៩២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២ | ១៦ | ៧០ |
| **ម៉ាស៊ីនទទួលកាបូបប្រាក់** | | | |
| ចំនួនម៉ាស៊ីនសរុប | ១៧ | ១៧ | ១៤ |
| ចំនួនប្រតិបត្តិការសរុប | ២២.៦៩៥ | ៧៥.០២០ | ៩៤.៧១៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៤០.០៧៣ | ៥៧១.០៩៨ | ៥៥៥.២៥៧ |
| **ម៉ាស៊ីនឆូតកាតអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនឆូតកាតសរុប | ៤.០២២ | ៤.៣៥៨ | ៤.៤៦២ |
| ចំនួនប្រតិបត្តិការសរុប | ៥៣៨.២១៩ | ២.១៥៩.១៧៥ | ២.០៣៣.២៤៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៦៩.១៥៧ | ៥៩១.៦០៣ | ៤៧៩.៦១៣ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី១ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
| **យូអរ ពាណិជ្ជករ** | | | |
| ចំនួនពាណិជ្ជករ | ២៨២.០៩៥ | ២៣៩.៧៥១ | ១២៥.៣០៩ |
| ចំនួនប្រតិបត្តិការសរុប | ២០.១៥៤.០០៧ | ១៦.៤៥៩.៣៧៧ | ៣.១៩៤.៤៤៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១១.៦៥៥.៨៧១ | ៧.៧៧៧.៤៩១ | ៦៣៨.២៤០ |
| **ប័ណ្ណនិម្មិតអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណនិម្មិត | ១២.៧៨៦ | ៨.៨៩៨ | ៣.៦៨៤ |
| ចំនួនប្រតិបត្តិការសរុប | ២០.៦១៣ | ៣៤.៩០៧ | ២.៤៩១ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២.០១៤ | ៣.០១៨ | ១៦១ |
| **ខ្សែអាយប៉េង** | | | |
| ចំនួនខ្សែបោះផ្សាយសរុប | ៨.៥៦៩ | ៤.៩៦០ | - |
| ចំនួនប្រតិបត្តិការសរុប | ៣.៥៥៨ | ១៨.៧៤២ | - |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៦.០២០ | ៣១.៧៦២ | - |
| **បណ្តាញប្រតិបត្តិការ និង បុគ្គលិក** | | | |
| **ធនាគារ អេស៊ីលីដា ភីអិលស៊ី** | | | |
| ចំនួនការិយាល័យសរុប | ២៦៤ | ២៦៤ | ២៦២ |
| ចំនួនធនាគារស្វ័យប្រវត្តិ | ១៤០ | ១២៥ | ៧៣ |
| ចំនួនបុគ្គលិកសរុប | ១២.០៥៩ | ១២.០៨៣ | ១២.០៨១ |
| **ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ក្នុង និង ក្រៅប្រទេស)** | | | |
| ចំនួនការិយាល័យសរុប | ៥៦ | ៥៦ | ៥៧ |
| ចំនួនបុគ្គលិកសរុប | ១.៥១៦ | ១.៤៩៩ | ១.៥៩៣ |

## ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី១ ឆ្នាំ២០២៣ | | ត្រីមាសទី១ ឆ្នាំ២០២២ | | ត្រីមាសទី១ ឆ្នាំ២០២១ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៧៥០.៧៥២ | ៩០,៨១% | ៦៣៨.០៤១ | ៨៩,៩០% | ៥៦៦.៦៦៨ | ៨៩,៣៥% |
| ២ | ចំណូលកម្រៃនិងជើងសា | ៤៧.៣៣៥ | ៥,៧៣% | ៤៧.៥០៦ | ៦,៦៩% | ៥០.៥៧៩ | ៧,៩៨% |
| ៣ | ចំណូលផ្សេងៗសុទ្ធ | ២៨.៦៨៣ | ៣,៤៧% | ២៤.១៤៩ | ៣,៤០% | ១៦.៩៣១ | ២,៦៧% |
| | **ចំណូលសរុប** | **៨២៦.៧៧០** | **១០០%** | **៧០៩.៦៩៦** | **១០០%** | **៦៣៤.១៧៨** | **១០០%** |

# ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ
របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ

# ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះផ្តោតសំខាន់លើលទ្ធផលប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេលគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុចន្លោះពេលត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក")។ មានតែសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេល និងកត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ធនាគារ អេស៊ីលីដាភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ ("សម្ព័ន្ធធនាគារ") ប៉ុណ្ណោះ ត្រូវបានយកមកធ្វើការពិភាក្សា និងវិភាគ។

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១- ការវិភាគចំណូល

សម្ព័ន្ធធនាគារ មានប្រភពចំណូលធំៗចំនួនបីគឺ ចំណូលការប្រាក់ ចំណូលកម្រៃនិងជើងសា និងចំណូលផ្សេងៗសុទ្ធ។

- ចំណូលការប្រាក់៖ រួមមានចំណូលការប្រាក់ពីឥណទាននិងបុរេប្រទាន ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងការវិនិយោគហិរញ្ញវត្ថុ។
- ចំណូលកម្រៃនិងជើងសា៖ រួមមានកម្រៃជើងសា កម្រៃជើងសាបានពីភ្នាក់ងារធានារ៉ាប់រង កម្រៃពីម៉ាស៊ីនអេធីអឹម កម្រៃពីការសងឥណទានមុនកាលកំណត់ កម្រៃពីសេវាប្រាក់បញ្ញើ កម្រៃពីសេវាធានា និងកម្រៃពីការបណ្តុះបណ្តាល។
- ចំណូលផ្សេងៗសុទ្ធ៖ រួមមានចំណេញពីការប្តូររូបិយប័ណ្ណ-សុទ្ធ ចំណេញពីការលក់ទ្រព្យនិងបរិក្ខារ ភាគលាភលើការវិនិយោគហិរញ្ញវត្ថុ និងចំណូលផ្សេងៗ។

### ២- ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី១ ឆ្នាំ២០២៣ | | ត្រីមាសទី១ ឆ្នាំ២០២២ | | ត្រីមាសទី១ ឆ្នាំ២០២១ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៧៥០.៧៥២ | ៩០,៨១% | ៦៣៨.០៤១ | ៨៩,៩០% | ៥៦៦.៦៦៨ | ៨៩,៣៥% |
| ២ | ចំណូលកម្រៃនិងជើងសា | ៤៧.៣៣៥ | ៥,៧៣% | ៤៧.៥០៦ | ៦,៦៩% | ៥០.៥៧៩ | ៧,៩៨% |
| ៣ | ចំណូលផ្សេងៗសុទ្ធ | ២៨.៦៨៣ | ៣,៤៧% | ២៤.១៤៩ | ៣,៤០% | ១៦.៩៣១ | ២,៦៧% |
| **ចំណូលសរុប** | | **៨២៦.៧៧០** | **១០០%** | **៧០៩.៦៩៦** | **១០០%** | **៦៣៤.១៧៨** | **១០០%** |

ចំណូលសរុបនៅត្រីមាសទី១ ឆ្នាំ២០២៣ បានកើនឡើងចំនួន ១១៧,០៧ ប៊ីលានរៀល ឬ ១៦,៥០% បើប្រៀបធៀបទៅនឹងត្រីមាសទី១ ឆ្នាំ២០២២ ដែលការកើនឡើងទាំងនេះគឺដោយសារប្រសិទ្ធភាពនៃផលិតផលនិងសេវាកម្មដ៏សម្បូរបែបរបស់ធនាគារក្នុងយុគសម័យឌីជីថល និងកំណើនអតិថិជន។

### ៣- ការវិភាគគម្លាតចំណេញដុល

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរបស់សម្ព័ន្ធធនាគារ បានរៀបចំក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីគម្លាតចំណេញដុលទេ។ ចំណូលការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់សរុបនឹងត្រូវយកមកបង្ហាញនៅក្នុងការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ ដូចខាងក្រោម។

## ៤- ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី១ ឆ្នាំ២០២៣ | ត្រីមាសទី១ ឆ្នាំ២០២២ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ៧៥០.៧៥២ | ៦៣៨.០៤១ | ១១២.៧១១ | ១៧,៦៧% |
| ចំណាយការប្រាក់ | (៣០៧.៨៨៧) | (១៩៤.៣៨០) | (១១៣.៥០៧) | ៥៨,៣៩% |
| **ចំណូលការប្រាក់សុទ្ធ** | **៤៤២.៨៦៥** | **៤៤៣.៦៦១** | **(៧៩៦)** | **(០,១៨%)** |
| ចំណូលកម្រៃនិងជើងសា | ៤៧.៣៣៥ | ៤៧.៥០៦ | (១៧១) | (០,៣៦%) |
| ចំណាយកម្រៃនិងជើងសា | (២.៦០១) | (៣.២២៣) | ៦២២ | (១៩,៣០%) |
| **ចំណូលកម្រៃនិងជើងសាសុទ្ធ** | **៤៤.៧៣៣** | **៤៤.២៨៣** | **៤៥០** | **១,០២%** |
| (សំវិធានធន)/ការកត់ត្រាត្រឡប់នៃការខាតបង់ឱនភាពនៃតម្លៃរបស់ឥណទាននិងបុរេប្រទានប្រាក់បញ្ញើនៅធនាគារផ្សេងៗ គណនីត្រូវទទួល និងមូលបត្រវិនិយោគផ្សេងៗ | (៤១.៦៣៥) | (៦៦.៤៣៦) | ២៤.៨០១ | (៣៧,៣៣%) |
| (សំវិធានធន)/ការកត់ត្រាត្រឡប់នៃការខាតបង់ឱនភាពនៃតម្លៃកិច្ចសន្យាក្រៅតារាងតុល្យការ | (៧) | ១៧ | (២៤) | ១៤១,១៨% |
| **ចំណាយពីការខាតបង់ឱនភាពនៃតម្លៃសុទ្ធ** | **(៤១.៦៤២)** | **(៦៦.៤១៩)** | **២៤.៧៧៧** | **(៣៧,៣០%)** |
| **ចំណូលបន្ទាប់ពីការខាតបង់ឱនភាពនៃតម្លៃ** | **៤៤៥.៩៥៦** | **៤២១.៥២៥** | **២៤.៤៣១** | **៥,៨០%** |
| ចំណូលផ្សេងៗសុទ្ធ | ២៨.៦៨៣ | ២៤.១៤៩ | ៤.៥៣៤ | ១៨,៧៨% |
| ចំណាយទូទៅនិងរដ្ឋបាល | (២៨៣.២៩៤) | (២៦៥.៩៩៣) | (១៧.៣០១) | ៦,៥០% |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **១៩១.៣៤៥** | **១៧៩.៦៨២** | **១១.៦៦៣** | **៦,៤៩%** |

ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញនៅត្រីមាសទី១ ឆ្នាំ២០២៣ បានកើនឡើងចំនួន ១១,៦៦ ប៊ីលានរៀល ឬ ៦,៤៩% បើប្រៀបធៀបទៅនឹងត្រីមាសទី១ ឆ្នាំ២០២២ ដោយសារប្រសិទ្ធភាពនៃផលិតផលនិងសេវាកម្មដ៏សម្បូរបែបរបស់ធនាគារក្នុងយុគសម័យឌីជីថល កំណើនអតិថិជន និងការគ្រប់គ្រងចំណាយប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ៥- ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី១ ឆ្នាំ២០២៣ | ត្រីមាសទី១ ឆ្នាំ២០២២ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **១៩១.៣៤៥** | **១៧៩.៦៨២** | **១១.៦៦៣** | **៦,៤៩%** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៣៣.៩២០) | (៣៦.០៧២) | ២.១៥២ | (៥,៩៧%) |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **១៥៧.៤២៤** | **១៤៣.៦១០** | **១៣.៨១៤** | **៩,៦២%** |

## ៦- ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| លទ្ធផលលម្អិតសរុប (លានរៀល) | ត្រីមាសទី១ ឆ្នាំ២០២៣ | ត្រីមាសទី១ ឆ្នាំ២០២២ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **១៥៧.៤២៤** | **១៤៣.៦១០** | **១៣.៨១៤** | **៩,៦២%** |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | |
| ***ធាតុដែលនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញទៅចំណេញ ឬខាត៖*** | | | | |
| ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | - | (៥.២០៥) | ៥.២០៥ | ១០០% |
| លម្អៀងពីអត្រាប្តូរប្រាក់ | (៨៤.០៦៥) | (២៩.២៩៥) | (៥៤.៧៧០) | (១៨៦,៩៦%) |
| ***ធាតុដែលត្រូវ ឬអាចត្រូវបានចាត់ថ្នាក់ឡើងវិញនៅគ្រាបន្ទាប់ទៅចំណេញ ឬខាត៖*** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ-ក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស | (២.២៦៣) | (១០.៧២៦) | ៨.៤៦៣ | ៧៨,៩០% |
| ការវាស់វែងឡើងវិញលើផ្នែកដែលមានប្រសិទ្ធភាពរបស់ឧបករណ៍និស្សន្ទដែលកើតឡើងពីការការពារហានិភ័យលំហូរសាច់ប្រាក់ | (៣.១៩០) | ១០.៦២១ | (១៣.៨១១) | (១៣០,០៣%) |
| **លទ្ធផលលម្អិតផ្សេងៗក្នុងការិយបរិច្ឆេទ** | **(៨៩.៥១៨)** | **(៣៤.៦០៥)** | **(៥៤.៩១៣)** | **(១៥៨,៦៩%)** |
| **លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | **៦៧.៩០៦** | **១០៩.០០៥** | **(៤១.០៩៩)** | **(៣៧,៧០%)** |

## ៧- ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ធនាគារ អេស៊ីលីដា មានទំនុកចិត្តក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការរបស់ខ្លួន ចំពេលការព្យាករកំណើនសេដ្ឋកិច្ចមានសញ្ញាល្អប្រសើរឡើង បន្ទាប់ពីបានកសាងកេរ្តិ៍ដំណែលដ៏រឹងមាំអស់រយៈពេល ៣០ឆ្នាំកន្លងមកនេះ ធនាគារ អេស៊ីលីដា បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ពេលអនាគត ហើយនឹងនៅតែបន្តចាក់គ្រឹះឱ្យកាន់តែរឹងមាំដើម្បីផ្តល់ជូន នូវដំណោះស្រាយក្នុងវិស័យធនាគារឱ្យកាន់តែសម្បូរបែប ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរតម្រូវការផ្នែកហិរញ្ញវត្ថុរបស់អតិថិជនទាំងនៅក្នុង និងក្រៅប្រទេសកម្ពុជា។

បន្ទាប់ពីបំបែកព្រំដែនភូមិសាស្ត្រ ដោយការដាក់បញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងរូបវន្ត ធនាគារដែលបានបង្កើតឡើងនៅក្នុងស្រុកមួយនេះ កំពុងផ្តល់ជូននូវសេវាកម្មធនាគារសម្រាប់មូលដ្ឋានអតិថិជនចម្រុះដោយជោគជ័យ ដែលមានរាប់ចាប់តាំងពីសេវាធនាគារបុគ្គល និងសម្រាប់សាជីវកម្ម ទាំងនៅក្នុងទីក្រុង រហូតដល់តំបន់ជនបទ។ ជាមួយនឹងភាពលេចធ្លោក្នុងការផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដ៏សម្បូរបែប ដូចជាផ្តល់ប្រាក់កម្ចី ផ្ទេរប្រាក់ ប្រាក់បញ្ញើ ហិរញ្ញប្បទានពាណិជ្ជកម្ម អេស៊ីលីដាអ៊ីនធើណែត **អេស៊ីលីដាម៉ូបាល** និងសេវាសំខាន់ៗជាច្រើនទៀត គាំទ្រដោយហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការិយាល័យរូបវន្តរបស់ខ្លួន ធនាគារ អេស៊ីលីដា កំពុងចូលរួមយ៉ាងសកម្មក្នុងការជួយដល់កសិករ តាមរយៈការផ្តល់ដើមទុនសម្រាប់ធ្វើស្រែចម្ការរបស់គាត់ ឬផ្តល់ទុនសម្រាប់សហគ្រាសធុនតូច និងមធ្យមជាដើម។ តាមរយៈការបង្រួមគម្លាតចំពោះការទទួលបានហិរញ្ញប្បទាន សព្វថ្ងៃ

នេះប្រជាជនកម្ពុជាច្រើនជាងកន្លះលាននាក់ មានលទ្ធភាពប្រើប្រាស់សេវារបស់ធនាគារ អេស៊ីលីដា ដែលជាការជំរុញនិងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។

សម្រាប់រយៈពេល៣០ឆ្នាំខាងមុខ គេនឹងមើលឃើញ ធនាគារ អេស៊ីលីដា គឺជា ធនាគារឌីជីថល ដែលមានវិស្វកម្មគ្រប់គ្រងទិន្នន័យទំនើបទាន់សម័យ (Data Lakehouse) ប្រកបដោយគុណភាព សុវត្ថិភាព និងទំនុកចិត្ត។ ប្រព័ន្ធអេកូនៃបណ្តាញប្រកបដោយប្រសិទ្ធភាពរបស់ធនាគារនៅទូទាំងប្រទេស រួមមានម៉ាស៊ីន ATM ទីតាំងធនាគារស្វ័យប្រវត្តិ ម៉ាស៊ីនដក-ដាក់ប្រាក់ ម៉ាស៊ីនបើកគណនីនិងបោះពុម្ពប័ណ្ណអេធីអឹម ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ កំពុងដើរតួជាកាតាលីករដ៏មានឥទ្ធិពលមួយសម្រាប់រលកនៃកំណើនបន្ទាប់។

អនាគតរបស់ធនាគារនឹងកាន់តែរឹងមាំ ខណៈទំនុកចិត្តរបស់អាជីវកម្មលើកំណើនសេដ្ឋកិច្ចរបស់កម្ពុជានឹងកើនឡើង បន្ទាប់ពីរាជរដ្ឋាភិបាលបានទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទស្សនៈវិស័យកំណើនរបស់ប្រទេសកម្ពុជា ត្រូវបានរំពឹងថានឹងងើបឡើងវិញនៅពេលដែលការរឹតបន្តឹងបញ្ហាកូវីដ-១៩ ត្រូវបានដកចេញ។

ការងើបឡើងវិញនៃការនាំចេញផ្នែកផលិតកម្ម និងការពង្រីកការនាំចេញទំនិញកសិកម្ម នឹងមានភាពល្អប្រសើរសម្រាប់ធនាគារអេស៊ីលីដា ដោយសារអ្នកទទួលកម្ចីភាគច្រើនមានអាជីវកម្មទាក់ទងនឹងកសិផល។ ធនាគារសម្រេចបានលទ្ធផលកាន់តែល្អប្រសើរនៅក្នុងឆ្នាំ២០២៣ ដោយសារធនាគារបានវិនិយោគយ៉ាងច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល សាងសង់មជ្ឈមណ្ឌលទិន្នន័យដ៏ធំមួយ ដែលមានសុវត្ថិភាពខ្ពស់ដើម្បីរក្សាទុកទិន្នន័យ។ ការសាងសង់មជ្ឈមណ្ឌលការពារទិន្នន័យ (Disaster Recovery Data Center) នឹងជួយរក្សាទិន្នន័យនៅក្នុងបរិយាកាសដែលមានការការពារខ្ពស់។ ធនាគារមានទំនុកចិត្តចំពោះពេលអនាគត ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងផលិតផល-សេវាកម្ម ដែលនឹងកាន់តែមានភាពល្អប្រសើរ។

## ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

សម្ព័ន្ធធនាគារ ទទួលបានជោគជ័យនៅលើទីផ្សារអាស្រ័យដោយកត្តាពីរគឺ៖

- កំណើនសំពៀតឥណទាន ដោយសារតម្រូវការខ្ពស់នៅលើទីផ្សារលើផលិតផលឥណទានរបស់សម្ព័ន្ធធនាគារ ជាពិសេសសហគ្រាសធុនតូច និងមធ្យម។
- កំណើនប្រាក់បញ្ញើ-សន្សំ របស់សម្ព័ន្ធធនាគារ រួមជាមួយផលិតផល និងសេវាកម្មផ្សេងទៀត។

កត្តាទាំងពីរនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងការអភិវឌ្ឍឥតឈប់ឈរនៃប្រព័ន្ធឌីជីថលរបស់សម្ព័ន្ធធនាគារ ដែលផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងទាន់សម័យ។

សម្ព័ន្ធធនាគារ បាននិងកំពុងតែអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធចម្រុះឱ្យកាន់តែទូលំទូលាយសម្រាប់ជាជម្រើសដ៏សម្បូរបែបជាមួយនឹងការិយាល័យទាំង៣២០ តាមរយៈការផ្លាស់ប្តូរបន្តិចម្តងៗទៅជាមជ្ឈមណ្ឌលដែលអាចធ្វើស្វ័យប្រតិបត្តិការដែលមានទីតាំងធនាគារស្វ័យប្រវត្តិចំនួន១៤០ ព្រមទាំងមាន **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** ចំនួន១.១១៤ គ្រឿង **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** ចំនួន២៦គ្រឿង **ម៉ាស៊ីនបើកគណនីនិងបោះពុម្ពប័ណ្ណអេធីអឹម** ចំនួន៩៦ គ្រឿង **ម៉ាស៊ីនទទួលកាបូបប្រាក់** ចំនួន១៧ គ្រឿង និង **ម៉ាស៊ីនឆូតកាត**ចំនួន៤.០២២ គ្រឿង។ ចំណុចគួរជាទីមោទនភាពគឺសម្ព័ន្ធធនាគារ បានបោះពុម្ពប័ណ្ណ**អេធីអឹមអេស៊ីលីដា** ចំនួន១,៨៥ លានប័ណ្ណជូនដល់អតិថិជន។ បន្ថែមលើនេះ សម្ព័ន្ធធនាគារ បានផ្តល់ **ខ្សែអាយប៉េង** ច្រើនជាង ៨ពាន់ខ្សែដល់អតិថិជន។ ទន្ទឹមនឹងនេះ **អេស៊ីលីដាម៉ូបាល** បានទទួលប្រជាប្រិយភាពយ៉ាងខ្លាំងដែលចំនួននៃអ្នកចុះឈ្មោះប្រើប្រាស់បានកើនដល់ ២,៩៨ លាននាក់នៅដំណាច់ខែមីនា ឆ្នាំ២០២៣នេះ ដែលអាចជួយឱ្យចរាចរសាច់ប្រាក់បានឆាប់រហ័សនៅក្នុងសេដ្ឋកិច្ច។

ការបង្កើនភាពងាយស្រួលដល់អតិថិជន និងពង្រឹងប្រព័ន្ធសុវត្ថិភាពអ៊ិនធើណែត គឺជាចំណុចដែលសម្ព័ន្ធធនាគារ ផ្តោតការយកចិត្តទុកដាក់បំផុត។ ដើម្បីសម្រេចនូវវឌ្ឍនភាពគោលដៅដ៏រឹងមាំទាំងនេះ សម្ព័ន្ធធនាគារ នឹងបន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមរយៈការវិនិយោគលើបច្ចេកវិទ្យាទំនើបចុងក្រោយ ពង្រឹងសមត្ថភាពធនធានមនុស្ស ព្រមទាំងពង្រីកនិងកែ

លម្អដំណើរការអាជីវកម្ម។ ជាយុទ្ធសាស្រ្ត សម្ព័ន្ធធនាគារកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដែលអាចឱ្យដៃគូទាំងក្នុង និងក្រៅប្រទេសអាចភ្ជាប់ប្រព័ន្ធនេះដើម្បីបម្រើអតិថិជនទៅវិញទៅមក និងឆ្លងព្រំដែន។ ប្រព័ន្ធនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់អតិថិជនដ៏ឆ្លាតវៃរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដៃគូអាជីវកម្មរបស់ពួកគាត់ផងដែរ។ យើងខ្ញុំទទួលស្គាល់ថាអតិថិជន និងដៃគូអាជីវកម្មទាំងអស់គឺជាបណ្តាញតភ្ជាប់ដ៏មានសារសំខាន់សម្រាប់ពង្រីកសេវាកម្មរបស់សម្ព័ន្ធធនាគារ និងរីកចម្រើនជាមួយគ្នា។

**អេស៊ីលីដាម៉ូបាល** ត្រូវបានកែលម្អយ៉ាងទូលំទូលាយ និងផ្លាស់ប្តូររូបរាងថ្មី កាន់តែទំនើប ងាយស្រួល និងមានសុវត្ថិភាពខ្ពស់ជាមួយនឹងមុខងារពិសេសៗជាច្រើន។ ឥឡូវនេះ អតិថិជនទាំងអស់អាចធ្វើប្រតិបត្តិការប្រាក់បញ្ញើ-សន្សំ (សំចៃ ចរន្ត និងមានកាលកំណត់) តាមរយៈ **អេស៊ីលីដាម៉ូបាល** បានភ្លាមៗ ថែមទាំងទទួលបានការប្រាក់ខ្ពស់ទៀតផង។

**ខេអេចឃ្យូអរកូត (KHQR Code)** ផ្តល់នូវភាពងាយស្រួលជាងមុនជូនដល់អ្នកប្រើប្រាស់ក្នុងការធ្វើប្រតិបត្តិការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងទំនុកចិត្តខ្ពស់ រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលជាសមាជិករបស់កម្មវិធីបាគង (**Bakong App**) ។

ឥឡូវនេះ ជាមួយ**អេស៊ីលីដាម៉ូបាល** ពិតជាងាយស្រួល ដោយលោកអ្នកអាចទូទាត់ផ្សេងៗ តាម QR Code (Scan QR) បានគ្រប់ទីកន្លែង នៅទូទាំងប្រទេសថៃ និងវៀតណាម ដោយឥតគិតថ្លៃសេវា។ នេះជាភាពជោគជ័យថ្មីមួយទៀតរបស់ប្រព័ន្ធបាគង និងធនាគារអេស៊ីលីដា ដែលជាសមាជិករបស់បាគង។

## ២- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រតិបត្តិការក្នុងវិស័យសេវាកម្ម ដែលការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនអាចអនុវត្តបានចំពោះធនាគារឡើយ។

## ៣- ការវិភាគលើពន្ធ

ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃប្រទេសនីមួយៗ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធមានកាតព្វកិច្ចបង់ពន្ធតាមការកំណត់របស់អាជ្ញាធរពន្ធដារនីមួយៗ។

ការបង់ពន្ធជូនអគ្គនាយកដ្ឋានពន្ធដារមិនត្រឹមតែជាកាតព្វកិច្ច និងការទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ **"មាស"** ពីអគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ២០២២ ដល់២០២៣ ប៉ុណ្ណោះទេ ប៉ុន្តែជាការចូលរួមចំណែកក្នុងសង្គម និងកំណើនសេដ្ឋកិច្ចផងដែរ។

ចំណូលពន្ធគឺជាប្រភពចំណូលដ៏សំខាន់បំផុតសម្រាប់ប្រទេស។ រដ្ឋាភិបាលប្រមូលពន្ធកាន់តែច្រើន ការចូលរួមវិភាគទានកាន់តែច្រើនដល់ការអភិវឌ្ឍប្រទេស។ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបង់ពន្ធច្រើនជាងគេជាប់ចំណាត់ថ្នាក់លេខ៣ និងបង់ពន្ធលើប្រាក់ចំណូលជាប់ចំណាត់ថ្នាក់លេខ៤ ក្នុងចំណោមសហគ្រាសដែលបានបង់ពន្ធច្រើនជាងគេប្រចាំឆ្នាំ២០២២។ ធនាគារអេស៊ីលីដា ភីអិលស៊ី មានមោទនភាពដែលអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើង។

## ៤- ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

សម្ព័ន្ធធនាគារ មិនមានធាតុ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលខុសពីធម្មតាជាសារវន្តនោះទេ។ ទោះជាយ៉ាងណាក៏ដោយលក្ខខណ្ឌសេដ្ឋកិច្ចដែលបានរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសវីរុសកូវីដ-១៩ បំប្លែងថ្មី ឆ្លងចូលក្នុងសហគមន៍ អាចជះឥទ្ធិពលដល់សមត្ថភាពសងត្រលប់មកវិញរបស់អតិថិជន ដែលគុណភាពឥណទានរបស់សម្ព័ន្ធធនាគារ អាចរងផលប៉ះពាល់បន្តិចបន្តួច។

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ដើម្បីចូលរួមគាំទ្រការរីកលូតលាស់អាជីវកម្មរបស់អតិថិជន សម្ព័ន្ធធនាគារ បានផ្តល់អត្រាការប្រាក់មានភាពប្រកួតប្រជែងខ្លាំងចំពោះការស្នើសុំឥណទានថ្មីគ្រប់ប្រភេទ និងដោយកាន់តែមានភាពងាយស្រួល អតិថិជនទាំងអស់អាចដាក់សំណើសុំឥណទានតាមរយៈ **អេស៊ីលីដាម៉ូបាល**។ ជាលទ្ធផល សមតុល្យឥណទានដុលសរុបនៅត្រីមាសទី១ ឆ្នាំ២០២៣ មានការកើនឡើងចំនួន ៣,២២ ទ្រីលានរៀល ឬ ១៣,៧៤% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២២។

## ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

សម្រាប់ត្រីមាសទី១ ឆ្នាំ២០២៣ តម្លៃទីផ្សារជាមធ្យមនៃប្រាក់រៀល (KHR) ធៀបនឹងដុល្លារអាមេរិក (USD) បានឡើងថ្លៃបន្តិចគឺពី ៤.១១៨ រៀលក្នុងមួយដុល្លារ នៅចុងខែធ្នូ ឆ្នាំ២០២២ ទៅ ៤.០៥៧ រៀលក្នុងមួយដុល្លារ នៅចុងខែមីនា ឆ្នាំ២០២៣។ ការប្រែប្រួលនេះ មួយផ្នែកគឺដោយសារតម្រូវការតាមរដូវកាល និងមួយផ្នែកទៀតជាការឆ្លុះបញ្ចាំងពីការកើនឡើងនៃតម្រូវការអ្នកប្រើប្រាស់ និងទំនុកចិត្តសាធារណជន ដែលអាចជួយបង្កើនអំណាចទិញ និងកាត់បន្ថយអតិផរណា។ ប្រមើលមើលទៅមុខ ក្រោមការគ្រប់គ្រងដ៏ប៉ិនប្រសប់របស់ធនាគារជាតិ នៃ កម្ពុជា (NBC) តម្លៃប្រាក់រៀលត្រូវបានរំពឹងថានឹងមានស្ថិរភាពដូចធ្លាប់មានពីមុនមក ការប្រែប្រួលតម្លៃរបស់ប្រាក់រៀលនឹងស្ថិតក្នុងបុព្វហេតុធម្មតានៃប្រតិបត្តិការអាជីវកម្ម និងតម្រូវការតាមរដូវកាលប្រើប្រាស់។

ចំពោះធនាគារ អេស៊ីលីដា ភីអិលស៊ី ធនាគារបានវាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងជាប្រចាំថ្ងៃ រក្សាបាននូវស្ថានភាពរូបិយប័ណ្ណចំហសុទ្ធតូច និងតែងតែគោរពតាមតម្រូវការបទប្បញ្ញត្តិរបស់ធនាគារជាតិ នៃ កម្ពុជា និងគោលនយោបាយហានិភ័យផ្ទៃក្នុងរបស់ខ្លួន។ ដូចនេះ មិនមានផលប៉ះពាល់ជាសារវ័ន្តពីអត្រាប្តូររូបិយប័ណ្ណចំពោះធនាគារឡើយ។

អត្រាការប្រាក់ទាំងទីផ្សារក្នុងស្រុក និងអន្តរជាតិបានបន្តរក្សាកម្រិតខ្ពស់បន្តិច បន្ទាប់ពីការកើនឡើងច្រើនដងនៃអត្រាមូលនិធិសហព័ន្ធនៃសហរដ្ឋអាមេរិក ដែលជាតម្រូវការសម្រាប់ការគ្រប់គ្រងដើម្បីកាត់បន្ថយអត្រាអតិផរណារបស់សហរដ្ឋអាមេរិក។

ទោះយ៉ាងណាក៏ដោយ សម្រាប់ធនាគារ អេស៊ីលីដា ធនាគារបានដំណើរការអាជីវកម្មរបស់ខ្លួនដោយផ្គូផ្គងរវាងទ្រព្យសកម្ម និងបំណុល លើអត្រាការប្រាក់ថេរ។ អាស្រ័យហេតុនេះ ផលប៉ះពាល់នៃការប្រែប្រួលអត្រាការប្រាក់លើអាជីវកម្មរបស់ធនាគារមានតិចតួចបំផុត ហើយរាល់ការប្រែប្រួលត្រូវបានត្រួតពិនិត្យជាប្រចាំ ដើម្បីចាត់វិធានការសមស្រប និងទាន់ពេលវេលា ដើម្បីចៀសវាងផលប៉ះពាល់ដល់អាជីវកម្មរបស់ធនាគារ។

ចំពោះតម្លៃទំនិញ (commodity prices) ធនាគារមិនបានផ្តល់សេវាបែបនេះទេ ដូចនេះមិនមានផលប៉ះពាល់ដល់ធនាគារឡើយ។

## ង- ផលប៉ះពាល់នៃអតិផរណា

សម្រាប់ឆ្នាំ២០២៣ អត្រាអតិផរណាជាមធ្យមត្រូវបានគេរំពឹងថានឹងថយចុះមកនៅត្រឹមប្រហែល ៣,២% ដោយសារតម្លៃប្រេង និងទំនិញផ្សេងទៀតត្រលប់មកកម្រិតប្រសើរជាងមុន។ អតិផរណាត្រូវបានព្យាករថានឹងថយចុះមកត្រឹម ៣,០% នៅឆ្នាំ២០២៤។ សម្រាប់ធនាគារ អេស៊ីលីដា ប្រតិបត្តិការរបស់ធនាគារមិនពាក់ព័ន្ធដោយផ្ទាល់ទៅនឹងកម្រិតអតិផរណានោះទេ។ ដូច្នេះផលប៉ះពាល់គឺតិចតួចបំផុត និងស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបាន។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល

- **<u>គោលនយោបាយសេដ្ឋកិច្ច៖</u>**

ធនាគារជាតិ នៃ កម្ពុជា បានផ្តល់ជារបាយការណ៍ថា កំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២២ បានបន្តងើបឡើងក្នុងអត្រា ៥,១% ដែលគាំទ្រជាចម្បងដោយការបើកទូលាយសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកឡើងវិញ និងកំណើនតម្រូវការខាងក្រៅ ដែលរួមមាន៖

១. វិស័យកម្មន្តសាលសម្រេចបានកំណើនរឹងមាំ ដែលក្នុងនោះផលិតផលកាត់ដេរសម្រាប់នាំចេញកើន ៦៤,៣% ផលិតផលមិនមែនកាត់ដេរសម្រាប់នាំចេញកើន ១,១ដង និងផលិតផលកម្មន្តសាលសម្រាប់បម្រើទីផ្សារក្នុងស្រុក កើន ៨៨,៥%។

២. វិស័យទេសចរណ៍មានកំណើនល្អ ដោយភ្ញៀវអន្តរជាតិបានកើនឡើងខ្ពស់ជាងការរំពឹងទុកដល់ ២,២ លាននាក់ ថ្វីបើនៅមានកម្រិតត្រឹម ១/៣ នៃគ្រាមុនវិបត្តិក៏ដោយ ខណៈដែលទេសចរក្នុងស្រុកបានវិលមកប្រក្រតីភាពទាំងស្រុង។
៣. វិស័យសំណង់ និងអចលនទ្រព្យមានកំណើនទាបត្រឹម ០,៨% និង ០,៥% រៀងគ្នា ដែលគាំទ្រដោយកំណើនតម្រូវការក្នុងស្រុក។
៤. វិស័យកសិកម្មបន្តកើនឡើងក្នុងល្បឿនយឺតត្រឹម ០,៧% ដែលបណ្តាលមកពីទឹកភ្លៀងធ្លាក់លឿននិងមានបរិមាណច្រើន និងការកើនឡើងថ្លៃដើមផលិត ដោយសារការឡើងថ្លៃប្រេងឥន្ធនៈ និងជីកសិកម្ម។
៥. ជញ្ជីងទូទាត់ត្រូវបានប៉ាន់ស្មានថាមានភាពប្រសើរឡើងដោយមានអតិរេក ២៩៨,៨ លានដុល្លារអាមេរិក ដោយសារលំហូរចូលនៃគណនីហិរញ្ញវត្ថុ និងការថយចុះឱនភាពគណនីចរន្ត និងដើមទុន។ ទុនបម្រុងអន្តរជាតិមានកម្រិតខ្ពស់គ្រប់គ្រាន់ ទោះបីជាបានថយចុះបន្តិចក្តី ដោយមានចំនួនប្រមាណ ១៧,៨ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ៧ខែ នៃការនាំចូលទំនិញ និងសេវាសម្រាប់គ្រាបន្ទាប់ ខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍ។

ស្របគ្នានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានព្យាករផងដែរថា សេដ្ឋកិច្ចកម្ពុជា ក៏សម្រេចបានកំណើន ៥,២% ផងដែរនៅឆ្នាំ ២០២២។ អត្រាកំណើននេះ គឺជាអត្រាមួយល្អបើធៀបនឹងអត្រាកំណើននៃបណ្តាប្រទេសក្នុងតំបន់ ដែលរួមចំណែកដោយ៖ វិស័យកម្មន្តសាលមិនមែនកាត់ដេរនៅតែបន្តរក្សាបានកំណើនល្អគ្រប់ត្រីមាស ដែលគាំទ្រដោយសក្តានុពលខ្ពស់នៃផលិតកម្មបម្រើឱ្យការនាំចេញ និងការបន្តកើនឡើងនៃផលិតកម្មសម្រាប់បម្រើទីផ្សារក្នុងស្រុក និងការងើបឡើងវិញនៃវិស័យទេសចរណ៍ និងសំណង់។ [(១),(២)]

យោងតាមព័ត៌មានដែលបានចុះផ្សាយរបស់ស្ថាប័នល្បីល្បាញមួយចំនួននៅបន្តព្យាករ GDP ឆ្នាំ២០២៣ របស់កម្ពុជាផងដែរ។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានព្យាករសេដ្ឋកិច្ចរបស់កម្ពុជាថានឹងកើនឡើង ៥,៥% ក្នុងឆ្នាំ២០២៣ និង ៦,០% ក្នុងឆ្នាំ២០២៤ លើការស្ទុះងើបឡើងវិញនៃវិស័យទេសចរណ៍ដ៏រឹងមាំ និងកំណើនខ្ពស់ក្នុងវិស័យសេវាកម្ម។ ទស្សនវិស័យអភិវឌ្ឍន៍អាស៊ី (ADO) ខែមេសា ឆ្នាំ២០២៣ និយាយថា វិស័យទេសចរណ៍ត្រូវបានគេរំពឹងថានឹងកើនឡើង ៧,៣% នៅឆ្នាំ២០២៣ មុនពេលបន្ធូរបន្ថយមកត្រឹម ៦,៨% នៅឆ្នាំ២០២៤។ ទិន្នផលឧស្សាហកម្មត្រូវបានគេរំពឹងថានឹងកើនឡើង ៥,៨% ក្នុងឆ្នាំ២០២៣ មុនពេលបង្កើនល្បឿនដល់ ៧,៨% ក្នុងឆ្នាំ២០២៤។ កំណើនសំណង់ត្រូវបានគេរំពឹងថានឹងនៅតែយឺត។ វិស័យកសិកម្មត្រូវបានព្យាករថានឹងកើនឡើង ១,១% នៅឆ្នាំនេះ និង ១,២% ក្នុងឆ្នាំ២០២៤ ដែលត្រូវបានជំរុញដោយផលិតកម្មដំណាំសម្រាប់ការនាំចេញ។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានព្យាករថា GDP សម្រាប់ប្រទេសកម្ពុជាគឺ ៥,៨% សម្រាប់២០២៣ និង ៦,២% សម្រាប់២០២៤ នេះបើយោងតាមការចុះផ្សាយនៅលើគេហទំព័ររបស់ពួកគេ។ ធនាគារពិភពលោកព្យាករកំណើនសេដ្ឋកិច្ច ៤,៨% ក្នុងឆ្នាំ២០២២ ខណៈដែលការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចក្រោយការរាតត្បាតរីករាលដាល ដោយសារការស្ទុះងើបឡើងវិញនៃវិស័យទេសចរណ៍ នេះបើតាមរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជារបស់ធនាគារពិភពលោកសម្រាប់ខែធ្នូ ឆ្នាំ២០២២ ដែលបានសរសេរថា ឧស្សាហកម្មកាត់ដេរ ទំនិញធ្វើដំណើរ និងការនាំចេញស្បែកជើងរបស់កម្ពុជាមានភាពធន់។ វិស័យសេវាកម្ម ជាពិសេសការធ្វើដំណើរ និងទេសចរណ៍ ធ្វើបានយ៉ាងល្អ ចាប់តាំងពីការដាក់ចេញនូវយុទ្ធសាស្ត្រ "រស់នៅជាមួយកូវីដ-១៩" នៅចុងឆ្នាំ២០២១ ហើយការមកដល់របស់ភ្ញៀវអន្តរជាតិសរុបបានកើនឡើងជាលំដាប់ ដោយឈានដល់ ១,២ លាននាក់ក្នុងរយៈពេល៩ខែដំបូងនៃឆ្នាំ២០២២។ ទំនុកចិត្តលើអាជីវកម្ម និងអ្នកប្រើប្រាស់បានកើនឡើង ហើយការវិនិយោគទាំងក្នុង និងក្រៅប្រទេសបានកើនឡើង។ កំណើនសេដ្ឋកិច្ចត្រូវបានព្យាករថានឹងកើនដល់ ៥,២% នៅឆ្នាំ២០២៣ ដោយសារការកើនឡើងនៃការជួលគាំទ្រដល់ការកើនឡើងនៃការប្រើប្រាស់ក្នុងស្រុក និងនៅពេលដែលអតិផរណាធ្លាក់ចុះ។ [(៣),(៤),(៥)]

- **គោលនយោបាយសារពើពន្ធ៖**

សម្រាប់ឆ្នាំ២០២៣ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវវិធានការសំខាន់ៗ និងជាយុទ្ធសាស្ត្រសំខាន់ៗដូចតទៅ៖
១. បន្តយកចិត្តទុកដាក់ និងពង្រឹងការអនុវត្តការងារស្របតាមអនុសាសន៍របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ជាទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ កាលពីកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំឆ្នាំ២០២២ នាថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣។
២. បន្តចូលរួមជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីប្រជុំជាមួយគណៈកម្មការទី២នៃរដ្ឋសភា និងកិច្ចប្រជុំពេញអង្គរដ្ឋសភា ព្រមទាំងប្រជុំជាមួយគណៈកម្មការទី២នៃព្រឹទ្ធសភា និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីសារពើពន្ធថ្មី។
៣. រៀបចំផែនការសកម្មភាពសម្រាប់ផ្សព្វផ្សាយច្បាប់ស្តីពីសារពើពន្ធថ្មី ជូនដល់អ្នកជាប់ពន្ធសាធារណៈ ព្រមទាំងក្រុមការងារវិស័យឯកជន និងអង្គការសមាគមនានា តាមគ្រប់រូបភាព។

៤. បន្តចូលរួមក្នុងក្របខ័ណ្ឌការងារប្រឆាំងនឹងបទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ជាមួយគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ.) និងអនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួម នៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិអន្តរជាតិ (អ.អ.ផ.)។

៥. រៀបចំប្រព័ន្ធដំណើរការការងាររដ្ឋបាលតាមទម្រង់ឌីជីថល (E-Administration) និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដើម្បីអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធអាចអនុវត្តការងារតាមឋានានុក្រម ដោយប្រើប្រាស់ទម្រង់ឌីជីថល និងធានាបាននូវល្បឿននិងប្រសិទ្ធភាពក្នុងការអនុវត្តការងារ។

៦. បន្តអនុវត្តវិធានការទារនិងតឹងទារបំណុលពន្ធតាមនីតិវិធីជាធរមាន ចំពោះសហគ្រាសដែលជំពាក់បំណុលពន្ធហើយមិនបានចូលខ្លួនមកទូទាត់ ឬដោះស្រាយឱ្យបានត្រឹមត្រូវ។

៧. បន្តរៀបចំយន្តការក្នុងការត្រួតពិនិត្យនិងគ្រប់គ្រងការកម្ទេចទំនិញខូចគុណភាពនិងកាត់ចេញពីស្តុករបស់សហគ្រាស។

៨. បន្តអនុវត្តវិធានការចុះអង្កេតសហគ្រាសតាមដងផ្លូវ (Street Survey) និងវិធានការចុះអង្កេតអចលនទ្រព្យ (Property Survey)។

៩. បន្តពង្រឹងការងារចុះបញ្ជីពន្ធដារនិងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស និងបន្តសហការចូលរួមកែលម្អ និងជំរុញការងារចុះបញ្ជីសហគ្រាសតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (CamDX) ឱ្យកាន់តែមានប្រសិទ្ធភាព និងមានភាពគ្រប់ជ្រុងជ្រោយ។

១០. បន្តផ្សព្វផ្សាយនិងពង្រឹងការអនុវត្តវិធានវិក្កយបត្រក្នុងចំណោមអ្នកជាប់ពន្ធ និងកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw) ឱ្យមានការចូលរួមបន្ថែមទៀតពីសាធារណជន ដើម្បីធានាបាននូវប្រសិទ្ធភាព និងតម្លាភាពក្នុងការគ្រប់គ្រងប្រមូលចំណូលពន្ធអាករនានា។

១១. បន្តពង្រឹងការងារពាក់ព័ន្ធនឹងពន្ធអចលនទ្រព្យក្នុងនោះ៖
   (ក) បញ្ចូលទិន្នន័យចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ
   (ខ) ផ្សព្វផ្សាយអំពីការបង់ពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់សម្រាប់ឆ្នាំ២០២៣ និង
   (គ) ពង្រីកវិសាលភាពអនុវត្តការបោះពុម្ពវិក្កយបត្រពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ ហើយចែកជូនដល់គេហដ្ឋានរបស់អ្នកជាប់ពន្ធ។

១២. បន្តពង្រឹងការគ្រប់គ្រងសហគ្រាសស្នើសុំផ្អាកបណ្តោះអាសន្ន ឬស្នើសុំបើកដំណើរការឡើងវិញ និង/ឬរទុកឬបើកដំណើរការវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម។

១៣. បន្តពង្រឹងនិងយកចិត្តទុកដាក់ចំពោះការស្នើសុំបិទសហគ្រាសជាស្ថាពរ និងពង្រឹងលើការងារសវនកម្មសម្រាប់សហគ្រាសស្នើសុំបិទ។

១៤. បន្តពង្រឹងការអនុវត្តកាតព្វកិច្ចដំឡើងឧបករណ៍វាស់ចំណុះស្រាបៀរ និងភេសជ្ជៈគ្មានជាតិអាល់កុលរបស់សហគ្រាសផលិតក្នុងស្រុក (Flowmeter) និងចុះពង្រឹងការត្រួតពិនិត្យជាក់ស្តែងតាមរោងចក្រសហគ្រាស ដើម្បីធានាបាននូវនិរន្តរភាពនៃវិធានការនេះ ជាពិសេស តម្លាភាព និងការប្រកួតប្រជែងស្មើភាព។

១៥. បន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងកម្មវិធីប្រកបដោយស្មារតីបុរេសកម្ម តាមរយៈការអភិវឌ្ឍនិងធ្វើបច្ចុប្បន្នភាពប្រព័ន្ធនិងកម្មវិធីថ្មីៗ បន្តវិនិយោគ និងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងពង្រឹងសមត្ថភាពមុខងារវិភាគទិន្នន័យបន្ថែមទៀត ដើម្បីជំរុញបង្កើនកម្រិតអនុលោមភាពសារពើពន្ធ ដោយធ្វើយ៉ាងណាឱ្យងាយស្រួលក្នុងការបំពេញកាតព្វកិច្ចពន្ធដារ ប៉ុន្តែពិបាកក្នុងការគេចវេះ តាមរយៈការបន្តអភិវឌ្ឍបន្ថែមនូវមុខងារមួយចំនួន ដែលទទួលបានពីអ្នកប្រើប្រាស់ពីគ្រប់មជ្ឈដ្ឋាន ដើម្បីឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយនិងងាយស្រួលក្នុងការប្រើប្រាស់។

១៦. បន្តអនុវត្តវិធានការបន្ថែមរបស់រាជរដ្ឋាភិបាលសម្រាប់បន្តគ្រប់គ្រងផលប៉ះពាល់ និងគាំទ្រការងើបឡើងវិញនៃវិស័យទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងបន្តកាត់បន្ថយផលប៉ះពាល់មកលើស្ថានភាពសង្គម-សេដ្ឋកិច្ចព្រមទាំងបន្តជួយទ្រទ្រង់ និងស្តារអាជីវកម្ម និងធុរកិច្ចឱ្យងើបឡើងវិញ។

១៧. អនុវត្តនូវវិធានការរបស់រាជរដ្ឋាភិបាលសម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យសំណង់ និងអចលនទ្រព្យដើម្បីរក្សាស្ថិរភាពនៃវិស័យសំណង់ និងអចលនទ្រព្យ ដែលត្រូវបានចាត់ទុកជាវិស័យអាទិភាពមួយគាំទ្រដល់កំណើនសេដ្ឋកិច្ចជារួម។

១៨. បន្តពង្រឹងការផ្តល់សេវាពិគ្រោះយោបល់ និងការផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ តាមគ្រប់រូបភាព ជាពិសេសការផ្តល់សេវាពិគ្រោះយោបល់តាមរយៈទូរស័ព្ទ (Call Center-1277) និងការរៀបចំកម្មវិធី "ពន្ធដារកម្ពុជា" (GDT Facebook Live) ដើម្បីពន្យល់និងដោះស្រាយការលំបាកនិងចម្ងល់របស់ប្រជាពលរដ្ឋ។

១៩. បន្តអនុវត្តវិធានការចាំបាច់នានា ដូចមានកំណត់ក្នុងសារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ និងបន្តអនុវត្តដោយការយកចិត្តទុកដាក់នូវយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣។

សរុបរយៈពេល៣ខែ ឆ្នាំ២០២៣ ចំណូលពន្ធ-អាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន ៥.៤៤២ ប៊ីលានរៀល (ប្រមាណជា ១.៣៤៣,៩០ លានដុល្លារអាមេរិក) ស្មើនឹង ៣៧,៦៣% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ បើប្រៀបធៀបនឹងចំណូលពន្ធ-អាករក្នុងរយៈពេលដូចគ្នា ឆ្នាំ២០២២ ឃើញថាកើនឡើងចំនួន ៣២៦,៩៧ ប៊ីលានរៀល (ប្រមាណជា ៨០,៧៣ លានដុល្លារអាមេរិក) ស្មើនឹង ៦,៣៩%។ ចំពោះលទ្ធផលនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ បានបង្ហាញថា ក្នុងខែមីនា ឆ្នាំ២០២៣ ចំណូលពន្ធ-អាករគ្រប់ប្រភេទ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែង តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារមានចំនួន ៣.២៥៨,០១ ប៊ីលានរៀល (ប្រមាណជា ៨០៤,៤៥ លានដុល្លារអាមេរិក) ស្មើនឹង ២២,៥២% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ បើប្រៀបធៀបនឹងចំណូលពន្ធ-អាករក្នុងរយៈពេលដូចគ្នា ឆ្នាំ២០២២ ឃើញថាកើនឡើងចំនួន ២១៧,៦៤ ប៊ីលានរៀល (ប្រមាណជា ៥៣,៧៤ លានដុល្លារអាមេរិក) ស្មើនឹង ៧,១៦%។ [៦]

- **គោលនយោបាយរូបិយវត្ថុ៖**

សម្រាប់ឆ្នាំ២០២២ ធនាគារជាតិ នៃ កម្ពុជា បានកំណត់អនុវត្តន៍គោលនយោបាយរូបិយវត្ថុចំនួន៥ ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារកំណើនសេដ្ឋកិច្ចជាតិ រួមមាន៖

(១) គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឱ្យស្ថិតក្នុងកម្រិតសមស្រប

(២) រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដើម្បីរួមចំណែកស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជន

(៣) លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលតាមយន្តការទីផ្សារ

(៤) អភិវឌ្ឍឧបករណ៍គោលនយោបាយរូបិយវត្ថុថ្មីៗ និង

(៥) ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ។ [៧]


ឯកសារយោង:

(១) https://www.nbc.org.kh/download_files/publication/annual_rep_kh/Annual%20Report%202022%20Publish_KHM.pdf

(២) https://mef.gov.kh/documents-category/publication/economic-finance-statistic-bulletin /Release on 20-Mar-2023

(៣) https://www.adb.org/news/cambodia-economy-accelerate-tourism-recovery-adb

(៤) https://www.imf.org/en/Publications/WEO/Issues/2023/04/11/world-economic-outlook-april-2023

(៥) https://www.worldbank.org/en/news/press-release/2022/12/07/cambodia-s-economy-is-recovering-but-could-face-headwinds-world-bank-report-says

(៦) https://www.tax.gov.kh/u6rhf7ogbi6/gdtstream/76a5b82f-f475-4d01-a25f-8a7c8cd721c6

(៧) https://www.nbc.org.kh/download_files/publication/annual_rep_kh/Annual%20Report%202021%20Publish.pdf


**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

ថ្ងៃព្រហស្បតិ៍ ៧រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣

ធនាគារ អេស៊ីលីដា ភីអិលស៊ី ACLEDA BANK PLC.

ប្រធានអាន និងឯកភាព

ហត្ថលេខា

**ឆាយ សឿន**

**ប្រធានក្រុមប្រឹក្សាភិបាល**

ការិយាល័យកណ្តាល ៖ អគារលេខ៦១ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ | ទូរសារ ៖ ០២៣ ៤៣០ ៥៥៥
acledabank@acledabank.com.kh | www.acledabank.com.kh
ប្រអប់សំបុត្រលេខ ៖ ១១៤៩ | SWIFT Code ៖ ACLBKHPP

ការិយាល័យទំនាក់ទំនងអតិថិជន (បម្រើ ២៤ម៉ោង)
ទូរស័ព្ទ ៖ ០២៣ ៩៩៤ ៤៤៤, ០១៥ ៩៩៩ ២៣៣
inquiry@acledabank.com.kh